

## សូមរក្សាម្ហូបអាហារ និងកាកសំណល់របស់លោកអ្នកនៅទីកន្លែងសុវត្ថិភាព

ការបណ្តោយអោយឆ្កែចចកទទួលបានអាហារ និងកាកសំណល់ របស់មនុស្ស គឺជាការធ្វេសប្រហែស និងអាចបណ្តាលអោយស្លាប់បាន ។ ជាដំបូងឆ្កែចចកដេញចាប់សត្វកកេរ និងទន្សាយធ្វើជាចំណី ប៉ុន្តែពួកវានឹងឆ្លៀតយកអត្ថប្រយោជន៍ពីអ្វីៗដែលវាអាចរកបាន រួមទាំងកាកសំណល់ចំណីសត្វ និងសត្វស្រុកនានា ។

- ចូរដាក់កាកសំណល់នៅក្នុងធុងបិទជិតយ៉ាងណែនដែលមិនអាចរលំបាន នៅពេលដើរទាក់វា ។
- ចូរយកចេញនូវប្រភពទឹក ជាពិសេសនៅពេលអាកាសធាតុក្តៅ ។ ចូរយកសត្វចិញ្ចឹមចូលទៅក្នុងផ្ទះនៅពេលយប់ និងមិនត្រូវដាក់ចំណីសត្វចោលនៅខាងក្រៅផ្ទះនោះទេ ។
- ចូរទុកចំណីបក្សីដោយឡែកនៅពេលយប់ដើម្បីចៀសវាងទាក់ទាញដល់ សត្វកកេរ និង សត្វដទៃទៀតជាចំណីឆ្កែចក ។
- ចូរផ្តល់នូវរបងដែលមានសុវត្ថិភាពដល់ទន្សាយ និងបក្សសុបក្សី ។ល។ ចូររើសចេញនូវផ្លែឈើដែលធ្លាក់ និងគ្របនូវគំនរសំរាមដែលរលួយ ។
- ចូរប្រាប់អ្នកជិតខាងរបស់អ្នកអោយធ្វើតាមការណែនាំទាំងនេះ។ សូមគោរព និងការពារសត្វព្រៃ និង រក្សាសត្វព្រៃអោយ រស់នៅតាមធម្មជាតិរបស់វា។

www.keepmewild.org

### សំរាប់ព័ត៌មានបន្ថែម

សូមទាក់ទងក្រសួងជលផល និងកីឡាបរបាញ់សត្វព្រៃរដ្ឋកាលីហ្វ័រញ៉ា California

**តំបន់ខាងជើង**

ទីក្រុងរីដឌិង Redding (៥៣០)២២៥-២៣០០

**តំបន់កណ្តាលភូមិភាគខាងជើង**

ទីក្រុងរិនកូក័រដូវ៉ា Rancho Cordova (៩១៦)៣៥៨-២៩០០

**តំបន់ឆ្នេរសមុទ្រដែលតា**

ទីក្រុងណាប៉ា Napa (៧០៧)៩៤៤-៥៥០០

**តំបន់កណ្តាល**

ទីក្រុងហ្វ្រេសណូ Fresno (៥៥៩)២៤៣-៤០០៥ លេខភ្ជាប់ ១៥១

**តំបន់ឆ្នេរសមុទ្រខាងត្បូង**

ទីក្រុងសិនដៃហ្គូ San Diego(៨៥៨)៤៦៧-៤២០១

**តំបន់សមុទ្រខ្សាច់អិនឡិន**

ទីក្រុងអ័នតារីយ៉ូ Ontario (៩០៩)៤៨៤-០១៦៧

**ការិយាល័យធំសាក្រាមិនតូ** Sacramento (៩១៦)៣២២-៨៩១១

ដើម្បីបញ្ជាទិញខិតប័ណ្ណបន្ថែម សូមទូរស័ព្ទមកកាន់លេខ (៩១៦)៣២២-៨៩១១ ឬផ្ញើសារអេឡិចត្រូនិកមកកាន់អាស័យដ្ឋាន publications@dfg.ca.gov

មធ្យោបាយទំនាក់ទំនងដទៃៗទៀតអាចធ្វើទៅបានតាមការស្នើសុំ ។ ប្រសិនបើមានតំរូវការស្នាក់នៅសមស្រប សូមទាក់ទងក្រសួងជលផលនិងកីឡាបរបាញ់សត្វព្រៃ លេខ (៩១៦)៣២២-៨៩១១

ឬសេវាបញ្ជូនបន្តរដ្ឋកាលីហ្វ័រញ៉ាដែលបំរើអ្នកស្រុកដែលមានបញ្ហាផ្នែក ត្រចៀក ប្រើប្រាស់ទូរស័ព្ទ TTY/TDD និងអ្នកស្រុកដែលមានបញ្ហាផ្នែកនិយាយ ទូរស័ព្ទលេខ (៨០០)៧៣៥-២៩២៩។

KEEP ME WILD™

យុទ្ធនាការដើម្បីសត្វព្រៃនៅទំនឹងឡាយ




## ការផ្តល់ចំណីដល់សត្វព្រៃ គឺជាកំហុសទាំងស្រុង

ក្រសួងជលផល និងសត្វព្រៃ
កាលីហ្វ័រញ៉ា

# សត្វព្រៃត្រូវបានវិនាសហិនហោច ព្រមទាំងត្រូវបានសំលាប់ដោយការធ្វេសប្រហែសរបស់មនុស្សទៀតផងដែរ !

សត្វព្រៃទាំងឡាយកំពុងមានការរំខាន ហើយបញ្ហាគឺបណ្តាលមកពី មនុស្ស ដែលមានការធ្វេសប្រហែសជាមួយនឹង ចំណីអាហារ និងកាកសំណល់ ។ ឆ្កែចចកមានតួនាទីសំខាន់ក្នុងប្រព័ន្ធបរិស្ថានវិទ្យា ដែលជួយរក្សាចំនួនសត្វកកេរអោយមានការត្រួតពិនិត្យបាន ។ ជាធម្មតាវាជា សត្វ ដែលគួរអោយខ្លាចចំពោះមនុស្ស ។

ប្រសិនបើសត្វឆ្កែចចកត្រូវបានគេអនុញ្ញាតិអោយទទួលទានអាហាររបស់មនុស្ស ចរិករបស់វានឹងមានការផ្លាស់ប្តូរ ។ វានឹងបាត់បង់ការប្រយ័ត្នប្រយែង និងភ័យខ្លាច ។ វានឹងបង្កអោយមានការខូចខាតទ្រព្យសម្បត្តិ ។ វាអាចនឹងកំរាមកំហែងដល់សុវត្ថិភាពរបស់មនុស្ស ហើយវានឹងអាចត្រូវបានគេសំលាប់ ។

ការតាំងលំនៅថ្មីនៃឆ្កែចចកដែលបង្កបញ្ហាមិនមែនជាជំរើសនោះទេ ពីព្រោះ វាគ្រាន់តែជាការផ្លាស់ប្តូរបញ្ហាទៅកាន់អ្នកដទៃទៀតនៅសង្កាត់ផ្សេងៗ តែប៉ុណ្ណោះ ។

សូមជួយបង្ការជំលោះដែលអាចអោយស្លាប់បាន
ចំពោះសត្វព្រៃដ៏ស្រស់ស្អាតនេះ ។



KEEP ME WILD™

យុទ្ធនាការដើម្បីសត្វព្រៃទាំងឡាយ

## ការប្រុងប្រយ័ត្ន ចំពោះ " សត្វឆ្កែចចកនៅតាមតំបន់"

- ចូរកុំអោយចំណី ឬព្យាយាមផ្សាំងឆ្កែចចកអោយសោះ ។ លទ្ធផលអាចមានជំលោះដែលអាចស្លាប់បាន ជាមួយសត្វចិញ្ចឹម ឬបសុសត្វ ឬរបួសធ្ងន់ធ្ងរដល់កុមារតូចៗ ។
- ចូរកុំទុកកុមារតូចៗ ឬសត្វចិញ្ចឹមនៅខាងក្រៅផ្ទះ ដោយគ្មានអ្នកនៅថែរក្សាអោយសោះ ។
- ចូរដាក់ភ្លើងបំភ្លឺដែលអាចដឹងបាននៅពេលមានចលនាជុំវិញផ្ទះ ។
- ចូរកាត់តំរឹមចុល្លព្រឹក្សាទាំងឡាយស្មើដីដើម្បីកាត់បន្ថយកន្លែងពួន ។
- ចូរអ្នកដឹងថា ឆ្កែចចកមានសកម្មភាពខ្លាំងបំផុតនៅក្នុងនិទាឃរដូវ នៅពេលដែលចិញ្ចឹម និងការពារកូនរបស់ពួកវា ។
- ប្រសិនបើត្រូវបានឆ្កែចចតាម ចូរបង្កសំលេងអោយបានខ្លាំងៗ ប្រសិនបើការនេះមិនបានសំរេច ចូរចោលដុំថ្មរទៅរកទីសដៅឆ្កែចចក ។
- ប្រសិនបើឆ្កែចចកវាយប្រហាមនុស្សណាម្នាក់ ចូរទាក់ទងជាបន្ទាន់ទៅក្រសួងជលផល និងកីឡាបរបាញ់សត្វព្រៃដែលនៅជិតបំផុត ឬការិយាល័យប្រត្តិបត្តិច្បាប់ ។ ក្រៅម៉ោងធ្វើការធម្មតាចូរទាក់ទង ៩១១ ។

សូមដាក់ម្ហូបអាហារនិងកាកសំណល់
របស់លោកអ្នកនៅទីកន្លែងសុវត្ថិភាព

## ធុងដែលធន់នឹងឆ្កែចចក



ចូប្រើប្រាស់ធុងសំរាមដែលមានគ្រឿងយន្តចាក់សោរនៅលើគំរប ។

ចូរប្រើប្រាស់ ខ្សែ ឬខ្សែកៅស៊ូដើម្បីចងធុងនៅនឹងរបង ឬវត្ថុរឹងមាំដទៃ ទៀតដើម្បីកុំអោយវារលំដួល ។

## ច្បាប់ថ្មី

ការអោចំណីសត្វឆ្កែចចកគឺច្បាប់នៅក្នុងសហគមន៍មួយចំនួន ។ បទប្បញ្ញតិនៅតាមតំបន់ជាច្រើនតំរូវការអោយចំណីសត្វព្រៃត្រូវបានធ្វើការផាកពិន័យ និងតំរូវអោយដាក់នូវធុងសំរាមការពារសត្វព្រៃទៀតផង ។




តំបន់ឆ្កែចចកធ្វើសកមភាពគ្រប់ដណ្តប់លើរដ្ឋកាលីហ្វ័រញ៉ាទាំងមូល ។ ជំលោះជាច្រើនកើតឡើងតាមព្រំដែនរវាងទីក្រុង និងតំបន់សត្វព្រៃ ។

## លោកអ្នកអាចជួយបាន

សូមទស្សនាគេហទំព័រ www.keepmewild.org សំរាប់ទាញយកប័ណ្ណប្រកាសការផ្សព្វផ្សាយពាណិជ្ជកម្មតាមសារពិតិមាន និងឯកសារមួយចំនួនទៀតទាក់ទងទៅនឹងការរក្សាសត្វព្រៃ ។